Minnesota Department of Health • ពត៌មានការពិតអំពីប្ប៉ៀភេរវកម្ម 10/11/2005

# Tularemia

## តើអ្វីជាធូឡារីមា?

ធូឡារីមាជាជម្ងឺមួយបណ្តាលមកពីបាក់តេរីម្យ៉ាង ដែលខ្លាំងនិងឆ្លងខ្លាំងណាស់។ វាអាចរស់បានទៅរាប់អាទិត្យ ក្នុងចំបើង ទឹក ដី និងខ្មោចសត្វ។



*ចៃអាចនាំចម្លងបាក់តេរី ធូឡារីមា*

រោគសញ្ញាធូឡារីមា មានប្លែកពីគ្នា តាមនឹងបែបដែលអ្នកប៉ះពាល់វា។ រោគសញ្ញានេះ មានដូចជា ដំបៅស្បែកហើមក្រពេញដែលឈឺខ្លាំង ភ្នែកក្លាយ ឈឺបំពង់ក ពងមាត់ ទឹកក្នុងសួត។ ប្រសិនបើ ដកដង្ហើមបាក់តេរីនេះចូល រោគសញ្ញាគឺ មានគ្រុនក្តៅភ្លាមៗ រងារ ឈឺក្បាល ឈឺសាច់ដុំ ឈឺគន្លាក់ឆ្អឹង ក្អកស្ងួត និងកម្លាំងខ្សោយទៅៗ។ ប្រសិនជាកើតឡើងទៅជាជម្ងឺសួតមានទឹក ធូឡារីមាអាចបណ្តាលឲ្យមានឈឺដើមទ្រូង ចេញឈាម ពិបាកដកដង្ហើម រឺការឈប់ដកង្ហើម។

រោគសញ្ញា ពេលភាគច្រើនបង្ហាញឲ្យឃើញមានឡើងពី៣ទៅ៥ថ្ងៃ បន្ទាប់ពីបានប៉ះពាល់ដល់បាក់តេរីរួចហើយ ប៉ុន្តែវាអាចឲ្យឃើញគ្រប់ពេលវេលាចន្លោះពេលពី១និង១៤ថ្ងៃ បន្ទាប់ពីបានប៉ះពាល់បាក់តេរីនេះរួច។

លើកលែងតែ មានការព្យាបាលនឹងថ្នាំផ្សះ មនុស្សដែលមានជម្ងឺសួត រឺការក្លាយទូទៅនៃរោគធូឡារីមា នឹងមានជម្ងឺធ្ងន់ធ្ងន់។ ដោយគ្មានការព្យាបាលនឹងថ្នាំផ្សះ មនុស្ស៣០ទៅ៦០ភាគរយ ដែលមានទំរង់នៃជម្ងឺនេះ អាចនឹងស្លាប់។

ប្រហែលជា២០០នាក់ក្នុង១ឆ្នាំ ក្នុងប្រទេស នឹងមានជម្ងឺធូឡារីមា ពីភពដើម ភាគច្រើននៅផ្នែកខាងលិច និងភាគកណ្តាលនៃខាងត្បូងក្នុងសហរដ្ឋ។ មានកើតឡើងដល់មនុស្ស៥នាក់ក្នុងរដ្ឋមីនីសូតា នៅកំលុងពេល១០ឆ្នាំកន្លងទៅ។

## តើអ្នកឆ្លងធូឡារីមាតាមបៀបណា?

ធូឡារីមាងាយនឹងឆ្លងណាស់ ពី១០ទៅ៥០បាក់តេរី អាចធ្វើឲ្យអ្នកមានជម្ងឺបាន។ ប្រភពធម្មជាតិនៃបាក់តេរី រាប់ទាំងសត្វតូចៗ ដូចជាកណ្តុរស្រែ កណ្តុរ កំប្រុក ទន្សាយ និងទន្សាយស្លឹក។

មនុស្សអាចឆ្លង :

- ពីតុកែខាំ រុយខាំ និងសត្វល្អិតឯទៀត
- ដោយប៉ះពាល់ដល់សត្វដែលមានរោគនោះ រឺខ្មោចសត្វ
- ដោយញ៉ាំអាហារ រឺប៉ះពាល់អាហារដែលខូច ទឹក រឺដី
- ដោយដកដង្ហើមចូលនូវបាក់តេរីលើអាកាស ដែលនៅក្នុងមន្ទីរពីសោធន៍ និងកន្លែងស្រដៀងនេះ

ការប្រើធូឡារីមាជាអាវុធ វាប្រហែលជាអាចទាក់ទងក្នុងការបញ្ចេញវាទៅក្នុងខ្យល់អាកាសនៅទីមានមនុស្សរស់នៅច្រើន។

## តើអាចឲ្យអ្នកឆ្លងរោគនេះពីមនុស្សឯទៀតបាន រឺទេ?

ការចម្លងជម្ងឺពីម្នាក់ទៅម្នាក់ទៀត មិនដែលមានដឹងថាកើតឡើងទេ។ វាក៏មិនអាចកើតឡើងបានដែរទេថា មនុស្សនឹងបន្តឆ្លងរោគ បន្ទាប់ពីបាក់តេរីបានបញ្ចេញទៅក្នុងខ្យល់អាកាសលើកមុនដំបូងបង្អស់នោះ។ គេបានជឿថា បាក់តេរីដែលបានបញ្ចេញទៅក្នុងខ្យល់អាកាស មិនរស់បានយូរទេ។

## តើហេតុអ្វីបានជាគេគឹតថា រោគនេះអាចយកមកប្រើជាអាវុធដ៏ឃោរឃៅបាន?

ទោះបីជាវាពិបាកក្នុងការធ្វើ ការបញ្ចេញធូឡារីមាទៅក្នុងខ្យល់អាកាស ក្នុងកន្លែងមានមនុស្សកកកុញ វាជាអាវុធដែលមានប្រសិទ្ធិភាពណាស់។ សញ្ញានៃការប្រហារធូឡារីមាដំបូងបង្អស់ គឺឃើញមានមនុស្សចាប់ផ្តើមរកការព្យាបាលនៅពេលប្រហែល៣ទៅ៥ថ្ងៃកន្លងមកទៀត។ មនុស្សជាច្រើននឹងស្លាប់ ប្រសិនបើមិនបានទទួលការព្យាបាលថ្នាំផ្សះទេនោះ។

MINNESOTA MDH DEPARTMENT OF HEALTH

Communications Office
625 North Robert Street/Box 64975
St. Paul, MN 55164-0975
(651) 201-4989
www.health.state.mn.us

# Tuleremia – ទំព័រទី 2

អង្គការសុខភាពសកលលោក (The World Health Organization) បានគណនាថា ៥០គីឡូក្រាម (១១០ ផោន) នៃបាក់តេរី ដែលបញ្ចេញទៅក្នុងអាកាសលើទីក្រុងនៃ៥លាននាក់ អាចបណ្តាលឲ្យមានបញ្ហាយ៉ាងធំ។ អង្គការសុខភាពសាកលលោកជឿថា ការវាយប្រហារបែបនេះ នឹងបណ្តាលឲ្យមនុស្ស ប្រហែល២៥ម៉ឺននាក់មានជម្ងឺធ្ងន់ និង១៩ពាន់នាក់ទៀតស្លាប់។

ធូឡារីមាមានលក្ខណៈខុសគ្នាច្រើន ដែលក្រសួងកាន់កាប់និងការពារជម្ងឺនៃសហរដ្ឋ ប្រើដើម្បីសំគាល់អាវុធនៃជម្ងឺជាអ្វីនោះ :

- មានវិធីងាយចម្លងរោគជាច្រើន ទោះបីជាវាមិនអាចចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតបានក៏ដោយ។
- វាមានឥទ្ធិពលធំមួយលើសុខភាពមនុស្ស រាប់ទាំងល្បឿននៃការស្លាប់។
- វាអាចមានចលាចលរាលពាសពេញ និងការរំខានដល់ជីវភាពរស់នៅ។
- វិធានការណ៍ពិសេសជាការចាំបាច់ ដើម្បីត្រៀមសំរាប់ការវាយប្រហារធូឡារីមា ដែលអាចនឹងកើតមាន

## តើអាចព្យាបាលរោគនេះបានរឺទេ?

ថ្នាំការពារត្រូវបានយកមកប្រើ ដើម្បីព្យាបាលរោគស្អួតនិងជម្ងឺទូទៅ ដែលបណ្តាលមកពីមេរោគដកដង្ហើមធូឡារីមា។ បើគ្មានការព្យាបាលទេ មនុស្ស៣០ទៅ៦០ភាគរយ ដែលមានរោគបែបនេះនឹងអាចស្លាប់។ បើមានការព្យាបាលវិញ ល្បឿននៃការស្លាប់នៅបច្ចុប្បន្ននេះសំរាប់ធូឡារីមាក្នុងសហរដ្ឋ គឺតិចជាង២ភាគរយ។

## តើអាចការពារកុំឲ្យមានរោគនេះបានរឺទេ?

នៅបច្ចុប្បន្ននេះ គ្មានថ្នាំការពារសំរាប់សាធារណៈទូទៅទេ។ ក្រសួងខាងអាហារនិងថ្នាំពេទ្យនៃសហរដ្ឋ នៅបច្ចុប្បន្ននេះ កំពុងតែសាកថ្នាំការពាររោគសំរាប់បុគ្គលិកដកការពិសោធ។

## តើអាចឲ្យខ្ញុំធ្វើយ៉ាងដូចម្តេច ប្រសិនបើគឺតថាខ្ញុំបានឆ្លងធូឡារីមាហើយនោះ?

ប្រសិនបើអ្នកបានប៉ះពាល់ធូឡារីមា វាមិនច្បាស់ថាអ្នកនឹងដឹងទេ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកព្រួយបារម្ភ សូមនិយាយជាមួយវេជ្ជៈបណ្ឌិតរបស់អ្នកភ្លាម។ ប្រសិនបើអ្នកឃើញកាលទេសៈ រឺសកម្មភាពដ៏សង្ស័យនៅក្នុងសហគមន៍របស់អ្នក រួមទាំងប្រើជម្ងឺជាអាវុធ សូមផ្តល់ពត៏មានដល់ក្រសួងសមត្ថកិច្ចតំបន់របស់អ្នក។